ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

លេខ៖ ប៣៥/២០២៦ កបទ.សអ

សេចក្តីប្រកាសព័ត៌មាន

លទ្ធផលនៃកិច្ចប្រជុំពិគ្រោះយោបល់ទ្វេភាគីលើកទី១ រវាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងការបរទេសដាណឺម៉ាក

នៅព្រឹកថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២៦ **ឯកឧត្តម នង សាកល** អនុរដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និង**លោក** Christian Tobias Bayer Tygesen ប្រធាននាយកដ្ឋានអាស៊ី អូសេអានី អាម៉េរិកឡាទីន និងតំបន់ខាងបៀន នៃក្រសួងការបរទេសដាណឺម៉ាក បានធ្វើជាសហប្រធានដឹកនាំកិច្ចប្រជុំពិគ្រោះយោបល់លើកទី១ រវាងកម្ពុជា-ដាណឺម៉ាក ដែលប្រព្រឹត្តទៅនៅរាជធានីភ្នំពេញ នៅទីស្តីការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា។ កិច្ចប្រជុំពិគ្រោះយោបល់នេះមានការចូលរួមពីតំណាងក្រសួងពាក់ព័ន្ធរបស់កម្ពុជាផងដែរ។

ក្នុងឱកាសកិច្ចប្រជុំពិគ្រោះយោបល់ខាងលើ ភាគីទាំងពីរបានចែករំលែកព័ត៌មាន អំពីការវិវត្តផ្នែកនយោបាយ សេដ្ឋកិច្ច និងសង្គម នៅក្នុងប្រទេសរៀងៗខ្លួន ព្រមទាំងបានលើកឡើង អំពីគោលនយោបាយអាទិភាពសំខាន់ៗ។ ភាគីទាំងពីរបានពិភាក្សា អំពីកាលានុវត្តភាពនានា ដើម្បីពង្រីកកិច្ចសហប្រតិបត្តិការទ្វេភាគីបន្ថែមទៀត លើវិស័យដែលមានផលប្រយោជន៍ទៅវិញទៅមក ដែលរួមមាន ពាណិជ្ជកម្ម ការវិនិយោគ ការអប់រំ សុខាភិបាល ទេសចរណ៍ និងវប្បធម៌។

ភាគីទាំងពីរបានអះអាងជាថ្មី អំពីភាពជាដៃគូដ៏រឹងមាំ និងកំពុងរីកចម្រើនរវាងកម្ពុជា និងដាណឺម៉ាក ហើយបានបង្ហាញក្តីជឿជាក់ថា កិច្ចពិគ្រោះយោបល់នេះ បានបង្កើតមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់ការធ្វើឱ្យទំនាក់ទំនងទ្វេភាគីកាន់តែស៊ីជម្រៅ។ ភាគីទាំងពីរបានសង្កត់ធ្ងន់លើការប្តេជ្ញាចិត្ត ក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការ និងរក្សាការសន្ទនាជាប្រចាំ ដើម្បីលើកកម្ពស់មិត្តភាព និងភាពជាដៃគូរវាងប្រទេសទាំងពីរឱ្យកាន់តែប្រសើរឡើង។

ភាគីទាំងពីរបានសង្កត់ធ្ងន់លើសារៈសំខាន់ នៃការជំរុញកិច្ចសហប្រតិបត្តិការជាក់ស្តែង រួមលុះចំណែកដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និងពង្រឹងទំនាក់ទំនងការទូត។ ក្នុងវិស័យពាណិជ្ជកម្ម និងការវិនិយោគ ភាគីទាំងពីរបានគូសបញ្ជាក់ពីសារៈសំខាន់នៃការពង្រឹងទំនាក់ទំនងរវាងវិស័យឯកជន ការ

ស្វែងរកកាលានុវត្តភាពវិនិយោគថ្មីៗ ការជំរុញសកម្មភាពធុរកិច្ច និងការសម្របសម្រួលលំហូរពាណិជ្ជកម្ម និងការវិនិយោគឱ្យកាន់តែទូលំទូលាយ ជាពិសេសនៅក្នុងវិស័យដែលមានសក្តានុពលខ្ពស់ដូចជា ថាមពល ឧស្សាហកម្មកែច្នៃកសិផល និងការគ្រប់គ្រងធនធានទឹក ក្នុងគោលបំណងគាំទ្រដល់កំណើនសេដ្ឋកិច្ច ប្រកបដោយចីរភាព។ ភាគីដាណឺម៉ាកក៏បានទទួលស្គាល់នូវសមិទ្ធផលសង្គម-សេដ្ឋកិច្ចរបស់កម្ពុជា ព្រមទាំងចក្ខុវិស័យ របស់កម្ពុជាក្នុងការចាកចេញពីឋានៈជាប្រទេសអភិវឌ្ឍន៍តិចតួច (LDC) នៅត្រឹមឆ្នាំ ២០២៩ ផងដែរ។

កិច្ចពិគ្រោះយោបល់នេះ ក៏បានផ្តល់ឱកាសផ្លាស់ប្តូរទស្សនៈលើកិច្ចសហប្រតិបត្តិការក្នុងក្របខណ្ឌ ពហុភាគី ជាពិសេសទំនាក់ទំនងរវាងអាស៊ាន-ដាណឺម៉ាក និងកម្ពុជា-សហភាពអឺរ៉ុប ព្រមទាំងបញ្ហាតំបន់ និងអន្តរជាតិដែលជាផលប្រយោជន៍រួមផងដែរ។ ក្នុងបរិបទនេះ ភាគីទាំងពីរបានបញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្ត របស់ខ្លួនចំពោះពហុភាគីនិយម និងច្បាប់អន្តរជាតិ។ ភាគីកម្ពុជាបានជម្រាបជូនភាគីដាណឺម៉ាកអំពីស្ថានភាព នៅតាមព្រំដែនកម្ពុជា-ថៃ និងបានបញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្តរបស់កម្ពុជាក្នុងការដោះស្រាយជម្លោះនានា ដោយសន្តិវិធី ស្របតាមច្បាប់អន្តរជាតិ និងកិច្ចព្រមព្រៀងដែលមានស្រាប់។

ក្នុងឱកាសនៃកិច្ចពិគ្រោះយោបល់នេះ ភាគីទាំងពីរបានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការបង្កើតយន្តការពិគ្រោះយោបល់ទ្វេភាគីរវាងក្រសួងការបរទេស នៃប្រទេសទាំងពីរ។

កិច្ចប្រជុំពិគ្រោះយោបល់នេះបានបញ្ចប់ទៅដោយជោគជ័យ ក្នុងបរិយាកាសដ៏កក់ក្តៅ និងស្និទ្ធស្នាល ដោយបានឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តរួមគ្នារបស់កម្ពុជា និងដាណឺម៉ាក ក្នុងការពង្រឹងទំនាក់ទំនងទ្វេភាគីបន្ថែមទៀត ព្រមទាំងបានបង្កើតក្របខណ្ឌដ៏សំខាន់មួយ សម្រាប់ការសន្ទនាជាប្រចាំ ការពង្រឹងកិច្ចសហប្រតិបត្តិការ និងការជំរុញគោលដៅរួមនានា។ កិច្ចប្រជុំពិគ្រោះយោបល់ទ្វេភាគីលើកទី២ នឹងប្រព្រឹត្តទៅនៅប្រទេសដាណឺម៉ាក។

ថ្ងៃ[illegible]ខែអស្សុជ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០២៦